6-L12-01, Level 12, Tower 2,
Menara PGRM
No. 6 & 8 JalanPudu Ulu, Cheras,
56100 Kuala Lumpur, Malaysia

Telephone: +00 (603) 9283 9881
Facsimile: +00 (603) 9284 8187
Email: ia.mysbaenquiry@intertek.com
Website: www.intertek.com

**ICI Ref: R9280/12-7 MRICOP – RA-01** ២៨ មេសា ២០១៦

**គោរពជូន ភាគីពាក់ព័ន្ធ**

<u>សេចក្តីអញ្ជើញចូលរួមផ្តល់យោបល់លើការវាយតម្លៃដើម្បីបន្តវិញ្ញាបនបត្រមាត្រដ្ឋាន RSPO (RA-01) RSPO របស់ក្រុមហ៊ុន ម៉ុង ឫទ្ធី វិនិយោគទុន ដំណាំដូងប្រេង កម្ពុជា (លេខសមាជិកភាព RSPO : 1-0109-11-000-00) ទៅលើអង្គភាពគ្រប់គ្រងចំការ ដូចជា រោងចក្រចម្រាញ់ប្រេងដូង និងកសិដ្ឋានដូងប្រេង នៅក្នុងខេត្ត ព្រះសីហនុ ប្រទេសកម្ពុជា</u>

ក្រុមហ៊ុន ម៉ុង ឫទ្ធី វិនិយោគទុន ដំណាំដូងប្រេង កម្ពុជា បានផ្តល់អោយស្ថាប័នវាយតម្លៃវិញ្ញាបនបត្រ Intertek Certification International Sdn Bhd សម្រាប់ការវាយតម្លៃ និងការធ្វើវិញ្ញាបនកម្មទៅលើអង្គភាពគ្រប់គ្រងរបស់ខ្លួនមានដូចជា រោងចក្រចម្រាញ់ប្រេងដូង និងកសិដ្ឋានដូងប្រេង ដោយអនុលោមទៅតាមតម្រូវការនៃគោលការណ៍ និងលក្ខណវិនិច្ឆ័យរបស់សមាគម RSPO (RSPO P&C) ឆ្នាំ២០១៣ និងស្របតាមសូចនាករជាតិប្រទេសកម្ពុជា (CLI) ឆ្នាំ២០១៤ និងប្រព័ន្ធវិញ្ញាបនបត្របណ្តាញផ្គត់ផ្គង់ RSPO ឆ្នាំ ២០១៤ (RSPO SCCS 2014) សម្រាប់រោងចក្រចម្រាញ់ប្រេងដូង។

Intertek Certification International មានផែនការណ៍ធ្វើការវាយតម្លៃដើម្បីបន្តវិញ្ញាបនបត្រមាត្រដ្ឋាន RSPO (RA-01) ទៅលើអង្គភាពគ្រប់គ្រងនៃក្រុមហ៊ុន ម៉ុង ឫទ្ធី វិនិយោគទុន ដំណាំដូងប្រេង កម្ពុជា មានដូចជា រោងចក្រចម្រាញ់ប្រេងដូង និងកសិដ្ឋានដូងប្រេង ពីថ្ងៃទី ៥ ដល់ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១៧។

ក្នុងការធានាថា ក្រុមហ៊ុន បន្តបំពេញតម្រូវការនៃគោលការណ៍ និងលក្ខណវិនិច្ឆ័យរបស់ RSPO សូចនាករជាតិប្រទេសកម្ពុជា និងប្រព័ន្ធវិញ្ញាបនបត្របណ្តាញផ្គត់ផ្គង់ RSPO សម្រាប់រោងចក្រចម្រាញ់ប្រេងដូង និងក្នុងការទទួលបាននូវព័ត៌មានត្រឹមត្រូវ ស្ថាប័ន Intertek Certification International Sdn Bhd សូមគោរពអញ្ជើញភាគីដែលមានចំណាប់អារម្មណ៍ ដើម្បីផ្តល់ជាយោបល់លើការវាយតម្លៃនៃក្រុមហ៊ុន ម៉ុង ឫទ្ធី វិនិយោគទុន ដំណាំងដូងប្រេង កម្ពុជា ទៅលើអង្គភាពគ្រប់គ្រងចំការ ៖ រោងចក្រចម្រាញ់ប្រេងដូង និងកសិដ្ឋានដូងប្រេង។ អង្គភាពវិញ្ញាបនកម្មមានទីតាំងនៅក្នុងខេត្ត ព្រះសីហនុ។

ដោយសង្ខេប ក្រុមហ៊ុន ម៉ុង ឫទ្ធី វិនិយោគទុន ដំណាំងដូងប្រេង កម្ពុជា បានក្លាយជាសមាជិកនៃសមាគម RSPO តាំងពីថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១ និងបានប្តេជ្ញាអនុវត្តតាមពេញលេញទៅតាមគោលការណ៍ និងលក្ខណវិនិច្ឆ័យរបស់ RSPO និងវិញ្ញាបនកម្មពេញលេញគ្រប់លក្ខណៈនៃប្រតិបត្តិការនានារបស់ខ្លួន។ ក្រុមហ៊ុន ម៉ុង ឫទ្ធី វិនិយោគទុន ដំណាំងដូងប្រេង កម្ពុជា គ្រប់គ្រង និងប្រតិបត្តិដំណើរការរោងចក្រចម្រាញ់ប្រេងដូងពីរ និងកសិដ្ឋានដូងប្រេងបួន។

សេចក្តីពិស្តារនៃរោងចក្រចម្រាញ់ប្រេងដូងពីរ និងកសិដ្ឋានដូងប្រេងបួន ដែលនឹងត្រូវបានធ្វើការវាយតម្លៃ គឺមានដូចខាងក្រោម៖

អង្គភាពគ្រប់គ្រងចំការ : រោងចក្រចម្រាញ់ប្រេងដូង និងកសិដ្ឋានដូងប្រេងរបស់ MRICOP

| ឈ្មោះ | អាសយដ្ឋាន | យោងលេខនិយាមកា | |
|---|---|---|---|
| | | រយៈទទឹង | រយៈបណ្តោយ |
| រោងចក្រចម្រាញ់ប្រេងដូងមនោរម្យ (សមត្ថភាព: ៣០ តោន/ម៉ោង) | ផ្លូវជាតិលេខ៤, ភូមិមនោរម្យ, ឃុំជើងគោ, ស្រុកព្រៃនប់, ខេត្តព្រះសីហនុ, កម្ពុជា | 10° 54' 33.7"N | 103° 50' 04.2"E |
| រោងចក្រចម្រាញ់ប្រេងដូងអន្ទង់ក្រពើ (សមត្ថភាព: ៤៥ តោន/ម៉ោង) | ផ្លូវជាតិលេខ៤, ភូមិអន្ទង់ក្រពើ, ឃុំជើងគោ, ស្រុកព្រៃនប់, ខេត្តព្រះសីហនុ, កម្ពុជា | 10° 57' 52.1" N | 103° 54' 26.2" E |
| កសិដ្ឋាន អេ (តាពៅ) | ផ្លូវជាតិលេខ៤, ភូមិតាពៅ, ឃុំជើងគោ, ស្រុកព្រៃនប់, ខេត្តព្រះសីហនុ, កម្ពុជា | 10° 48' 59.7"N | 103° 47' 46.9"E |
| កសិដ្ឋាន ប៊ី (ស្វាយ) | ផ្លូវជាតិលេខ៤, ភូមិស្វាយ, ឃុំជើងគោ, ស្រុកព្រៃនប់, ខេត្តព្រះសីហនុ, កម្ពុជា | 10° 52' 08.2"N | 103° 51' 19.2"E |
| កសិដ្ឋាន ស៊ី (អន្ទង់ក្រពើ) | ផ្លូវជាតិលេខ៤, ភូមិអន្ទង់ក្រពើ, ឃុំជើងគោ, ស្រុកព្រៃនប់, ខេត្តព្រះសីហនុ, កម្ពុជា | 10° 57' 58.7"N | 103° 54' 02.0"E |
| កសិដ្ឋាន ឌី (គីរីវ័ន្ត) | ផ្លូវជាតិលេខ៤, ភូមិគីរីវ័ន្ត, ឃុំស្ទឹងឆាយ, ស្រុកកំពង់សិលា, ខេត្តព្រះសីហនុ, កម្ពុជា | 10° 57' 58.4"N | 103° 54' 01.9"E |

| ឈ្មោះកសិដ្ឋាន | អាសយដ្ឋាន | ដូងពេញវ័យ* (ហ.ត) | ដូងមិនពេញវ័យ* (ហ.ត) | សរុបផ្ទៃដី* | | ទិន្នផលផ្លែដូងប្រចាំឆ្នាំ (តោន) * |
|---|---|---|---|---|---|---|
| | | | | វិញ្ញាបនបត្រ (ហ.ត) | ដាំដូង (ហ.ត) | |
| កសិដ្ឋាន អេ (តាពៅ) | ផ្លូវជាតិលេខ៤ ភូមិតាពៅ ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កម្ពុជា | 4,073.68 | 0.00 | 6,705.47 | 4,073.68 | 57,869.11 |
| កសិដ្ឋាន ប៊ី (ស្វាយ) | ផ្លូវជាតិលេខ៤ ភូមិស្វាយ ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កម្ពុជា | 4,287.52 | 0.00 | 7,667.86 | 4,287.52 | 38,769.98 |
| កសិដ្ឋាន ស៊ី (អន្ទង់ក្រពើ) | ផ្លូវជាតិលេខ៤ ភូមិអន្ទង់ក្រពើ ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កម្ពុជា | 3,705.12 | 614.51 | 5,351.24 | 4,319.63 | 18,365.98 |
| កសិដ្ឋាន ឌី (គីរីវ័ន្ត) | ផ្លូវជាតិលេខ៤ ភូមិគីរីវ័ន្ត ឃុំស្ទឹងឆាយ ស្រុកកំពុងសិលា ខេត្តព្រះសីហនុ កម្ពុជា | 2,005.57 | 1,783.50 | 5,118.85 | 3,789.07 | 7,871.13 |
| **Total** | | **14,071.89** | **2,398.01** | **24,843.42** | **16,469.90** | **122,876.20** |

* ឆ្នាំ កក្កដា ២០១៥ / មិថុនា ២០១៦

| ឈ្មោះរោងចក្រ | អាសយដ្ឋាន | ផលិតប្រចាំឆ្នាំ* | | សមត្ថភាព (តោន / ម៉) |
|---|---|---|---|---|
| | | ប្រេង (តោន) | គ្រាប់ (តោន) | |
| រោងចក្រចម្រាញ់ប្រេងដូង មនោរម្យ | ផ្លូវជាតិលេខ៤ ភូមិមនោរម្យ ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កម្ពុជា | 10,428.55 | 2,129.16 | 30 |
| រោងចក្រចម្រាញ់ប្រេងដូង អន្ទង់ក្រពើ | ផ្លូវជាតិលេខ៤ ភូមិអន្ទង់ក្រពើ ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កម្ពុជា | 13,259.66 | 2,865.84 | 45 |

* ឆ្នាំ កក្កដា ២០១៥ / មិថុនា ២០១៦

ស្ថាប័ន Intertek Certification International Sdn Bhd [អតីតត្រូវបានគេស្គាល់ថា ជាស្ថាប័ន Moody International Certification (Malaysia) Sdn Bhd] គឺជាផ្នែកមួយនៃគ្រុប Intertek Group ដែលជាអង្គការផ្តល់សេវាកម្មបច្ចេកទេសជាសកលមួយ ដោយផ្តោតទៅលើការកាត់បន្ថយហានិភ័យរបស់អតិថិជន ដោយផ្តល់សេវាកម្មត្រួតពិនិត្យបច្ចេកទេស វិញ្ញាបនបត្រប្រព័ន្ធគ្រប់គ្រង ទៅលើគុណភាព បរិស្ថាន សុវត្ថិភាព និងសុខភាពនៅកន្លែងការងារ និងការបញ្ជាក់ពីផលិតផល វិញ្ញាបនបត្របណ្តាញផ្គត់ផ្គង់របស់សមាគម RSPO (RSPO SCC)

វិញ្ញាបនបត្របណ្តាញផ្គត់ផ្គង់អន្តរជាតិ (ISCC) ខាងបណ្តាញគាំពារផ្នែកដើងទឹកប្រកបដោយចីរភាព MTCS និងវិញ្ញាបនបត្របណ្តាញគាំពារ PEFC នៅក្នុងវិស័យឧស្សាហកម្មដែលអាចអនុវត្តបាន រួមទាំងវិស័យកសិកម្ម និងព្រៃឈើ។ ស្ថាប័ន Intertek ប្រតិបត្តិទូទាំងសកលលោកក្នុងការផ្តល់នូវភាពជំនាញខាងអធិការកិច្ច បច្ចេកទេសយ៉ាងទូលំទូលាយ និងអាចទទួលបាននូវអ្នកឯកទេសដ៏មានជំនាញនៅក្នុងសកលលោក។ ជំនួញវិញ្ញាបនបត្ររបស់គ្រុប Intertek Group គឺត្រូវបានជាប់ចំណាត់ថ្នាក់ ក្នុងលំដាប់កំពូលទាំង ១០ នៅទូទាំងពិភពលោក និងមានលទ្ធភាពជាសកល ក្នុងការផ្តល់វិញ្ញាបនបត្រ ក្នុងវិស័យឧស្សាហកម្ម ដ៏ទូលំទូលាយ។

ស្ថាប័ន Intertek Certification International Sdn Bhd បានចាត់តាំងក្រុមសម្រាប់ការវាយតម្លៃដូចខាងក្រោម៖

- ប្រធានក្រុមអ្នកវាយតម្លៃ
  - Mr. Augustine Loh (ខាងរោងចក្រចម្រាញ់ប្រេងដូង ការប្រើប្រាស់ដី និងបណ្តាញផ្គត់ផ្គង់នៅរោងចក្រ)
- អ្នកវាយតម្លៃ
  - Mr. Chin Bit Kee (ពិគ្រោះយោបល់ភាគីពាក់ព័ន្ធ ផ្នែកច្បាប់ ការអនុវត្តកសិកម្មល្អ និងវិធានការចម្រុះថែទាំដំណាំ)
  - Mr. Sazali Bin Hasni (ពិគ្រោះយោបល់ភាគីពាក់ព័ន្ធ ផ្នែកច្បាប់ បរិស្ថាន និងតំបន់ដែលមានតម្លៃខ្ពស់សម្រាប់អភិរក្ស និងតំបន់អភិរក្ស)
  - Mr. Jumat Bin Majid (ពិគ្រោះយោបល់ភាគីពាក់ព័ន្ធ ផ្នែកច្បាប់ សង្គម សុវត្ថិភាព និងសុខភាពនៅកន្លែងការងារ)
  - Mr. Reaksa Rous (អ្នកជំនាញក្នុងស្រុក - ច្បាប់ និងប្បញ្ញត្តិក្នុងស្រុក)

ដោយផ្អែកទៅលើការវាយតម្លៃ ដែលនឹងធ្វើឡើងនៅទីតាំងដូចដែលបានរៀបរាប់ខាងលើ ស្ថាប័ន Intertek Certification International Sdn Bhd សូមស្វាគមន៍ភាគីពាក់ព័ន្ធ ដើម្បីផ្តល់នូវមតិយោបល់ទៅលើបញ្ហានានា ខាងក្រោម ដែលទាក់ទងទៅនឹងទីតាំងដែលនឹងត្រូវធ្វើការវាយតម្លៃ៖

- ការការពារបរិស្ថាន
- ឱកាសការងារ
- ការអភិរក្សជីវៈចម្រុះ
- ការអភិវឌ្ឍន៍សហគមន៍
- បញ្ហាដទៃទៀតដែលទាក់ទងសម្រាប់ការវាយតម្លៃ

រាល់មតិយោបល់ដែលនឹងត្រូវទទួលក្នុងកំឡុងពេល ៣០ ថ្ងៃ ចាប់តាំងពីការបរិច្ឆេតនៃលិខិតនេះ នឹងយកទៅពិចារណានៅក្នុងការវាយតម្លៃវិញ្ញាបនបត្រ។ សូមផ្តល់មតិយោបល់ដោយផ្ទាល់ទៅ

លោក Augustine Loh
ប្រធានកម្មវិធី RSPO
Intertek Certification International Sdn Bhd
6-L12-01, Level 12, Tower 2, Menara PGRM,
No. 6 & 8, Jalan Pudu Ulu Cheras,
56100 Kuala Lumpur, Malaysia
Tel: 603 9283 9881 Fax: 603 9284 8187
Email: augustine.loh@intertek.com

លោក Sumate Pratumsuwan
អគ្គនាយកក្រុមហ៊ុន
Mong Reththy Investment Camodia Oil Palm Co.Ltd
ភូមិមនោរម្យ ឃុំជើងគោ ស្រុកព្រៃនប់ ព្រះសីហនុ
Tel: (855-85) 903 551
Fax: (855-23) 216 496
Email: summate.p@tccagroindustrial.com

យើងសូមអរគុណសម្រាប់មតិយោបល់ និងយោបល់ត្រឡប់របស់អស់លោកអ្នក
ដោយសេចក្តីគោរព

______________________________
Augustine Loh
ប្រធានកម្មវិធី RSPO
Intertek Certification International Sdn Bhd